ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៧៨០៤ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្តាល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកណ្តាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្តាល មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌខាងក្រៅពណ៌មាស ខាងក្នុងព័ទ្ធដោយផ្កាវដ្ឋលពណ៌មាស និងខ្សែវណ្ឌខាងក្នុងពណ៌មាស បង្ហាញអំពីផាសុកភាព បរិស្ថានស្អាត និងការគ្រប់គ្រងដែនដីរបស់រដ្ឋបាលក្រុង

- ពញាខ្មៅ ឬលោកតាខ្មៅមានពណ៌ប្រផេះ សម្លៀកបំពាក់ពណ៌ខ្មៅ និងពណ៌ក្រហម ឈ្នួតក្បាលនឹងកន្សែងពណ៌ក្រហម និងដៃកាន់ព្រះរាជសារ គង់លើទម្រប៊ីថ្នាក់ពណ៌លឿងនិងពណ៌ត្នោត។ ពញាខ្មៅ ជាតំណាងនៃមេទ័ពខ្លាំងពូកែ ក្លាហាន អង់អាច និងចេះមន្តនិងសិល្បសាស្ត្រក្នុងការដឹកនាំគ្រប់គ្រង ការពារ និងថែរក្សាទឹកដី និងប្រជាជននៅសម័យដើម ហើយប្រជាជននិយមហៅទៅជាឈ្មោះភូមិ ឬក្រុងតាខ្មៅ
- វត្ត ឬអារាមតាខ្មៅ បង្ហាញអំពីការគោរពបូជារបស់ប្រជាជន ឬពុទ្ធបរិស័ទក្នុងជំនឿព្រះពុទ្ធសាសនា ហើយក៏ជាទីកន្លែងអប់រំ និងថែរក្សាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ប្រជាជនខ្មែរ
- ផ្ទៃទឹកពណ៌ខៀវខ្ចី បង្ហាញអំពីផ្ទៃទឹកទន្លេបាសាក់ដែលជាប្រភពទឹកសម្រាប់បម្រើវិស័យកសិកម្ម មនុស្ស សត្វ និងការដឹកជញ្ជូនផ្សេងៗ
- ផ្លូវថ្នល់និងវាលបៃតងខ្ចី បង្ហាញអំពីការរីកដុះដាលនូវគមនាគមន៍ផ្លូវគោក ដំណាំហូបផ្លែ និងបន្លែបង្ការ
- ស្លឹកក្រប្រាំពីរកាំពណ៌លឿងទ្រដោយផ្កាក្បាច់ភ្ញីទេសពណ៌មាស បង្ហាញអំពីខ្សែចង្វាក់ផលិតកម្ម នៃកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សិប្បកម្ម និងវប្បធម៌ នៅក្នុងក្រុង
- អក្សរឈ្មោះ«រដ្ឋបាលក្រុងតាខ្មៅ»មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្ដាល ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្ដាល ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលក្រុងតាខ្មៅ
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលក្រុងតាខ្មៅ
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាខេត្តកណ្ដាល អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល ប្រធានក្រុមប្រឹក្សាក្រុងតាខ្មៅ និងអភិបាលនៃគណៈអភិបាលក្រុងតាខ្មៅ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៗ.

ថ្ងៃ..ចន្ទ..១៣កើត...... ខែ..មិគសិរ..ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៦.....ខែ.....ធ្នូ.......ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកណ្ដាល
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...៣៤៩០៤...ប្រក ចុះថ្ងៃ...ចន្ទ ១រោច........ខែ..មិគសិរ..... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី...១៦....ខែ...ធ្នូ......ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្ដាល។

**និមិត្តសញ្ញារដ្ឋបាលក្រុងតាខ្មៅ**